# ក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន (EJC)
# កិច្ចប្រជុំលើកទី #10
# ថ្ងៃព្រហស្បតិ៍ 21 កញ្ញា 2023
# ពីម៉ោង 6:00 យប់ ដល់ ម៉ោង 7:30 យប់
# កំណត់ហេតុកិច្ចប្រជុំ

**ទីកន្លែងប្រជុំ៖** កិច្ចប្រជុំតាមប្រព័ន្ធ Zoom
**ឯកសារកិច្ចប្រជុំ៖** Agenda, slides
**សមាជិកក្រុមប្រឹក្សាដែលមានវត្តមាន៖**

- Kalila Barnett
- Melissa Ferretti
- Caroline Hon
- Namrita Kapur
- Sofia Owen
- Patricia Spence
- Jen Salinetti
- Marcos Luna
- Lydia Lowe
- Cheryll Holley

**មន្ត្រីការិយាល័យប្រតិបត្តិផ្នែកថាមពលនិងកិច្ចការបរិស្ថានដែលមានវត្តមាន៖**

- María Belén Power អនុលេខាធិការនៃក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន
- Carline Lemoine អនុប្រធានយុត្តិធម៌បរិស្ថានទទួលបន្ទុកសម្របសម្រួលជាមួយភាគីពាក់ព័ន្ធខាងក្រៅ

## 1. មតិស្វាគមន៍ និងទិដ្ឋភាពទូទៅនៃកិច្ចដំណើរការប្រជុំ

**María Belén Power** បានថ្លែងស្វាគមន៍វាគ្មិន និងអ្នកចូលរួម។ **Kecil John** បានរៀបរាប់អំពីទិដ្ឋភាពរួមនៃភស្តុភាររបស់កិច្ចប្រជុំ រួមទាំងការប្រើប្រាស់ប្រអប់សំណួរចម្លើយ និងវត្តមានរបស់អ្នកបកប្រែ។

## 2. ការត្រួតពិនិត្យវត្តមាន/ការអនុម័តកំណត់ហេតុកិច្ចប្រជុំមុន

- María Belén បានហៅឈ្មោះសមាជិករបស់ក្រុមប្រឹក្សាយុត្តិធម៌បរិស្ថានដើម្បីកត់ត្រាវត្តមាន។ នៅពេលចាប់ផ្តើមកិច្ចប្រជុំ សមាជិកក្រុមប្រឹក្សាដូចខាងក្រោម មានវត្តមានចូលរួម៖ **Kalila Barnett, Namrita Kapur, Lydia Lowe, Melissa Ferretti, Caroline Hon, Marcos Luna, Sofia Owen, Jen Salinetti, Patricia Spence,** និង **María Belén**។
- សមាជិករបស់ក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន ដូចខាងក្រោម អវត្តមាន នៅពេលចាប់ផ្តើមកិច្ចប្រជុំ ក៏ប៉ុន្តែ បានចូលរួមនាពេលបន្ទាប់៖ **Cheryll Holley**
- សមាជិករបស់ក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន ដូចខាងក្រោម អវត្តមាន៖ **Madeline Fraser Cook, Peter Maathey,** និង **Ari Zorn**។
- **María Belén** បានបើកកិច្ចប្រជុំដោយផ្តល់វេទិកាឲ្យអ្នកចូលរួម ស្នើសុំធ្វើការអនុម័តកំណត់ហេតុនៃកិច្ចប្រជុំមុន។ **Patricia Spence** ស្នើសុំធ្វើការអនុម័តកំណត់ហេតុ។ **Lydia Lowe** គាំទ្រសំណើនោះ។ **María Belén** ធ្វើការបោះឆ្នោតដោយហៅឈ្មោះអ្នកចូលរួម។ សមាជិកក្រុមប្រឹក្សាទាំងអស់ទទួលយកកំណត់ហេតុ។

## 3. វេទិកាសំណួរចម្លើយសាធារណៈលើកទី១

សំណួររបស់អ្នកចូលរួមសាធារណៈនិងកិច្ចពិភាក្សាដោយក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន រួមបញ្ចូលប្រធានបទដូចខាងក្រោម៖

- ការបកស្រាយបំភ្លឺអំពីច្បាប់របស់យុត្តិធម៌បរិស្ថាន ពាក់ព័ន្ធនឹងរោងចក្រថាមពលនៅ Taunton
- ការកំណត់អត្តសញ្ញាណប្រជាជនយុត្តិធម៌បរិស្ថាននៅក្នុងសហគមន៍

- ការបង្កើតផែនទីយុត្តិធម៌បរិស្ថានដោយប្រើប្រាស់ទិន្នន័យជំរឿនបរិស្ថាន
- ការធ្វើបច្ចុប្បន្នកម្មនិយមន័យយុត្តិធម៌បរិស្ថាន និង
- សក្តានុពលសម្រាប់ការបង្កើតក្រុមការងារច្បាប់គោលនយោបាយបរិស្ថានរដ្ឋម៉ាសាឈូសិត។

មតិយោបល់ដែលទទួលបានពីវេទិកាសំណួរចម្លើយ មានដូចខាងក្រោមៈ

| # | សំណួរ | ឈ្មោះអ្នកសួរ |
|---|---|---|
| 1 | តើក្រុមប្រឹក្សាយុត្តិធម៌បរិស្ថានមានផែនការបែបណាចំពោះវិធីសាស្ត្រ "សិទ្ធិធម្មជាតិ" ដើម្បីធ្វើឲ្យក្រុមកុលសម្ព័ន្ធ អាចការពារធនធានបរិស្ថានដែលចាំបាច់ចំពោះជីវភាពរស់នៅរបស់ពួកគេ? | David Dow |
| 2 | ខ្ញុំមានក្តីកង្វល់ខ្លាំងអំពីយុត្តិធម៌បរិស្ថាន ពាក់ព័ន្ធនឹងអាងទន្លេ Fore River (Quincy, Weymouth, និង Braintree)។ ដោយសារតែនេះគឺជាកិច្ចប្រជុំលើកទី១០របស់ក្រុមប្រឹក្សានេះ តើសកម្មភាព/ការសម្រេចចិត្ត/គោលនយោបាយអ្វីខ្លះ ត្រូវបានអនុវត្ត ដោយផ្អែកលើអនុសាសន៍របស់ក្រុមប្រឹក្សានេះ? | Peter Delano |
| 3 | បញ្ហាដ៏សំខាន់មួយដែលមិនទាន់បានដោះស្រាយ គឺកម្រិតនៃភាពចាំបាច់ សម្រាប់ជំរុញឲ្យមានការពិនិត្យវាយតម្លៃឡើងវិញដោយMEPA ។ គម្រោងដាច់ដោយឡែកៗនានា នៅក្នុងសហគមន៍យុត្តិធម៌បរិស្ថាន អាចស្ថិតនៅក្រោមកម្រិតដែលមានស្រាប់របស់ MEPA (ហេតុដូច្នេះ មិនតម្រូវឲ្យមានការកែលម្អការពិនិត្យវាយតម្លៃឡើងវិញនោះឡើយ) ចំណែកឯខ្សែបន្ទាត់គោលត្រួតដែលមានស្រាប់ នៃផលប៉ះពាល់អវិជ្ជមាន មានភាពចាំបាច់ ហើយគម្រោងដាច់ដោយឡែកៗនានាដែលបានស្នើឡើង បានបន្ថែមទៅដល់ផលប៉ះពាល់ត្រួត ជាប្រវត្តិសាស្ត្រ តើ EEA ក្រុមប្រឹក្សា និងលោកអភិបាល Healey នឹងដោះស្រាយបញ្ហានេះនៅពេលណា? | Frank O'Brien |

**4. កិច្ចពិភាក្សារបស់ EEA ស្តីពីភស្តុភារសម្រាប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាននាពេលអនាគត**

- សមាជិកក្រុមប្រឹក្សា ឯកភាពរៀបចំកិច្ចប្រជុំឆ្លាស់គ្នារវាងកិច្ចប្រជុំរបស់ក្រុមការងារ និងកិច្ចប្រជុំផ្លូវការរបស់ក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន ម្តងក្នុងមួយខែ។
- សមាជិកក្រុមប្រឹក្សា ឯកភាព រៀបចំកិច្ចប្រជុំឡើងវិញ នៅរៀងរាល់ខែបន្ទាប់ នៅថ្ងៃដូចគ្នានៃខែនីមួយៗ។
- កិច្ចប្រជុំរបស់ក្រុមការងារ នឹងត្រូវរៀបចំ នៅក្នុងខែ "បិទ"។ ក្រុមការងារអាចជួបប្រជុំដោយពុំចាំបាច់អនុលោមតាមច្បាប់ស្តីពីកិច្ចប្រជុំបើកចំហរ ប្រសិនបើពុំអាចទទួលបានកូរ៉ុមគ្រប់គ្រាន់។

**5. កិច្ចពិភាក្សារបស់EEA ស្តីពីទីតាំងសម្រាប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាននាពេលអនាគត**

- ទីតាំងដែលត្រូវបានស្នើឡើងរួមមាន Brockton, Mashpee, Worcester, North Adams, Holyoke/Springfield, Roxbury, Lynn/Salem, Stockbridge, Lowell/Lawrence, Taunton, Leominster, និង Framingham។
- សមាជិកក្រុមប្រឹក្សា ស្នើរៀបចំកិច្ចប្រជុំហាយប្រ៊ីឌ (hybrid) ដើម្បីអនុញ្ញាតឲ្យមាន ការចូលរួមដោយផ្ទាល់ និងតាមអនឡាញ។ ការចូលរួមតាមអនឡាញ នឹងត្រូវរាប់បញ្ចូលទៅក្នុងចំនួនកូរ៉ុម។
- សមាជិកក្រុមប្រឹក្សា ក៏បានស្នើសុំបង្កើតពិធីសារស្តង់ដារមួយ នៅពេលចាំបាច់ត្រូវផ្លាស់ប្តូរពីកិច្ចប្រជុំហាយប្រ៊ីឌ (hybrid) ទៅកិច្ចប្រជុំអនឡាញទាំងស្រុង។

6. **កិច្ចពិភាក្សារបស់EEA ស្តីពីអាទិភាពរបស់ការិយាល័យយុត្តិធម៌បរិស្ថាន**
   - María Belén បានបង្ហាញនូវទិដ្ឋភាពរួមនៃកិច្ចការងារដែលកំពុងត្រូវអនុវត្ត នៅការិយាល័យយុត្តិធម៌បរិស្ថាន។
   - ការិយាល័យយុត្តិធម៌បរិស្ថាន មានគោលដៅប្រមូលមតិយោបល់ពីសាធារណជន ស្តីពីគម្រោង គោលនយោបាយ និងវិធីសាស្រ្តបន្ថែមនានា ដោយធានាថាមតិយោបល់ទាំងនោះ នឹងត្រូវរួមបញ្ចូលទៅក្នុងលទ្ធផលនានា។
   - នាពេលបច្ចុប្បន្ន កំពុងបំពេញការងារលើយុទ្ធសាស្រ្តយុត្តិធម៌បរិស្ថាន កំពុងគាំទ្រទីភ្នាក់ងារ ពាក់ព័ន្ធនានា និងធានាថាមតិយោបល់នានា នឹងត្រូវដាក់រួមបញ្ចូល តាមរយៈការិយាល័យប្រតិបត្តិនិងទីភ្នាក់ងារទាំងអស់នៅក្រោម EEA។
   - ការិយាល័យ ក៏កំពុងពិនិត្យអត្ថប្រយោជន៍ ទល់នឹងបន្ទុក ដោយពិនិត្យមើល កិច្ចព្រមព្រៀងស្តីពីអត្ថប្រយោជន៍សហគមន៍ និងការបង្កើតក្រុមការងារ Justice40 ដែលផ្តោតលើការធានាថាការវិនិយោគនានា កំពុងត្រូវចែកចាយទៅដល់សហគមន៍ យុត្តិធម៌បរិស្ថានដោយអនុលោមតាមគំនិតផ្តួចផ្តើមJustice40 និងគំនិតផ្តួចផ្តើមរបស់រដ្ឋ ។

7. **កិច្ចពិភាក្សាអំពីមូលនិធិកាត់បន្ថយការបំពុលអាកាសធាតុ**
   - **Jonathan Schrag** មកពីការិយាល័យរបស់លោកអភិបាល បានចូលរួមពិភាក្សាអំពីមូលនិធិ កាត់បន្ថយការបំពុលអាកាសធាតុ។ គាត់បានបង្ហាញពីទិដ្ឋភាពទូទៅនៃកិច្ចដំណើរការដែលសហគមន៍ត្រូវអនុវត្ត ដើម្បីទទួលបានមូលនិធិ។
   - Jonathan បានពន្យល់ថា Boston; Worcester; និង Providence, Rhode Island នឹងទទួលបានថវិកាប្រហែល មួយលានដុល្លារអាមេរិក។
   - វិធានការអាទិភាព កំពុងត្រូវកំណត់អត្តសញ្ញាណដើម្បីរកឲ្យឃើញថាតើវិធានការមួយណា ដែលនឹងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់បានច្រើនបំផុត និងផ្តល់អត្ថប្រយោជន៍ ច្រើនដល់ប្រជាជនយុត្តិធម៌បរិស្ថាន។ ឧទាហរណ៍មួយនៃវិធានការអាទិភាព គឺការកាត់បន្ថយការបញ្ចេញឧស្ម័ន ពីយានយន្តធុនធ្ងន់ ចំនួន២០ភាគរយនៅត្រឹមឆ្នាំ២០៣០។ វិធានការនេះ នឹងត្រូវផ្តល់អាទិភាព បើប្រៀបធៀបទៅនឹងវិធានការកាត់បន្ថយការបញ្ចេញ ឧស្ម័នដោយរថយន្តធ្វើដំណើរធម្មតា ពីព្រោះយានយន្តធុនធ្ងន់បញ្ចេញឧស្ម័ន ដែលបង្កដោយចំហេះប្រេងម៉ាស៊ូតខ្ពស់ជាង។ ការផ្តល់មូលនិធិរបស់CPRG កំពុងស្ថិតនៅដំណាក់កាលរៀបចំផែនការនៅឡើយ។
   - សមាជិកក្រុមប្រឹក្សា បានពិភាក្សាអំពីភាពតភ្ជាប់រវាងផ្លូវឆ្លងកាត់ដែលមានចីរភាព និងដែលអាចប្រើប្រាស់បាន ការផ្លាស់ប្តូរទៅកាន់ផ្លូវឆ្លងកាត់ដែលដំណើរការដោយអគ្គិសនី លទ្ធភាពដែលរដ្ឋម៉ាសាឈូសិតអាចនឹងទទួលបានមូលនិធិសម្រាប់ការអនុវត្ត និងភាពចាំបាច់នៃការចែកចាយមូលនិធិដោយសមធម៌រវាងតំបន់ជនបទនិងទីក្រុង។

8. **បច្ចុប្បន្នភាពអំពីយុទ្ធសាស្រ្តយុត្តិធម៌បរិស្ថាននិងកិច្ចពិភាក្សា**
   - Carline Lemoine បានផ្តល់ជូននូវបច្ចុប្បន្នភាពអំពីយុទ្ធសាស្រ្តយុត្តិធម៌បរិស្ថាន ដែលកំពុងអនុវត្តអស់រយៈពេលប្រហែលពីរឆ្នាំកន្លះមកហើយ។
   - ក្រុមការងាររបស់យុត្តិធម៌បរិស្ថាន កំពុងខិតខំកែលម្អនិងដាក់បញ្ចូលបម្រែបម្រួលនានា ដើម្បីឆ្លុះបញ្ចាំងនូវមតិយោបល់ដែលទទួលបានកាលពីរដូវរងារ។ មតិយោបល់សាធារណៈ ផ្តោតជាចម្បងលើការបង្កើនការទទួលបានព័ត៌មានរបស់សាធារណជន របៀបដែលទីភ្នាក់ងារ ធ្វើការកំណត់អត្តសញ្ញាណនិងវាស់វែងវឌ្ឍនភាព និងរបៀបដែលគោលការណ៍យុត្តិធម៌បរិស្ថាន នឹងត្រូវដាក់រួមបញ្ចូលទៅក្នុងយុទ្ធសាស្រ្តយុត្តិធម៌បរិស្ថានដែលត្រូវបានបង្កើតឡើង។
   - ថវិកាដែលត្រូវបានផ្តល់ដោយការិយាល័យរបស់អភិបាល សម្រាប់ឆ្នាំសារពើពន្ធនេះ បានបែងចែកប្រហែល2លានដុល្លារអាមេរិក សម្រាប់សេវាបកប្រែ ដែលនេះគឺជាឧទាហរណ៍មួយ នៃការកែលម្អការទទួលបានព័ត៌មាន។ ឯកសារសំខាន់ៗ នឹងត្រូវផ្តល់ជូន ជាភាសាផ្សេងៗគ្នាជាច្រើន។

- យុទ្ធសាស្ត្រចុងក្រោយ ត្រូវបានកំណត់ពេលវេលាជាបណ្ដោះអាសន្នថានឹងត្រូវដាក់ចេញនៅត្រឹមចុងឆ្នាំនេះ ហើយវានឹងដើរតួជាឯកសាររស់ និងត្រូវពិនិត្យកែសម្រួលប្រហែលរៀងរាល់បីឆ្នាំម្ដង។

## 9. កិច្ចពិភាក្សារបស់ក្រុមការងារ

- ក្រុមការងារទាំងប្រាំ ដែលត្រូវបានស្នើឡើងនៅគ្រាដំបូង រួមមាន ក្រុមការងារនិយមន័យយុត្តិធម៌បរិស្ថាន ការចូលរួមប្រកបដោយអត្ថន័យនិងយុទ្ធសាស្ត្រយុត្តិធម៌បរិស្ថាន Justice40 កិច្ចព្រមព្រៀងស្ដីពីអត្ថប្រយោជន៍សម្រាប់សហគមន៍ និងអត្ថប្រយោជន៍ទល់នឹងបន្ទុក។
- សមាជិកក្រុមប្រឹក្សា សម្រេចផ្ដោតលើក្រុមការងារចំនួនពីរ គឺក្រុមការងារJustice 40និងក្រុមការងារនិយមន័យយុត្តិធម៌បរិស្ថាន។
- **María Belén** បានស្នើសុំសមាជិកក្រុមប្រឹក្សា លើកដៃដើម្បីចូលរួមក្នុងក្រុមការងារនីមួយៗដែលពួកគេចាប់អារម្មណ៍។
  - សម្រាប់ក្រុមការងារនិយមន័យយុត្តិធម៌បរិស្ថាន សមាជិកក្រុមប្រឹក្សា **Melissa Ferretti, Caroline Hon, Marcos Luna, Cheryll Holley, Jen Salinetti, និង Sofia Owen** បានស្ម័គ្រចិត្តចូលរួម។
  - សម្រាប់ក្រុមការងាJustice40 សមាជិកក្រុមប្រឹក្សា **Kalila Barnett, Lydia Lowe, and Patricia Spence** បានស្ម័គ្រចិត្តចូលរួម។
- **María Belén** នឹងផ្ញើតពិនិត្យបន្ថែម តាមរយៈអ៊ីម៉ែល ស្ដីពីក្រុមការងារនិងភស្ដុភារ និងការរៀបចំតារាងពេលវេលា។
- អ្នកជំនាញ នឹងទទួលបានការអនុញ្ញាតឲ្យអញ្ជើញចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមការងារ។

## 10. វេទិកាសំណួរចម្លើយសាធារណៈលើកទី២

- អ្នកចូលរួមម្នាក់ សម្ដែងនូវចំណាប់អារម្មណ៍ចំពោះការផ្សព្វផ្សាយនៅខាងក្រៅឲ្យបានកាន់តែច្រើន នៅ Taunton និង Massachusetts។ María Belén បានផ្ដល់ព័ត៌មានលម្អិតអំពីវេទិកាស្ដាប់មតិយោបល់នាពេលអតីតកល និងធ្វើការកត់សម្គាល់ដើម្បីដាក់បញ្ចូលTauntonទៅក្នុងវេទិកាស្ដាប់មតិយោបល់នាពេលអនាគត។

មតិយោបល់ដែលទទួលបានពីវេទិកាសំណួរចម្លើយ មានដូចខាងខក្រោម៖

| # | សំណួរ | ឈ្មោះ |
|---|---|---|
| 1 | ក្រុមកុលសម្ព័ន្ធ កំពុងរិះរកវិធីគ្រប់គ្រងត្រីហារ៉ុងនៅក្នុងទន្លេដែលបន្តពូជនៅក្នុងទន្លេនានានៅក្នុងតំបន់នៅក្នុងដែនដីរបស់ក្រុង ប៉ុន្តែស្ថិតនៅខាងក្រៅដែនអភិរក្ស។ | David Dow |
| 2 | ចំពោះអនុសាសន៍របស់ក្រុមការងារស្ដីពីអត្ថប្រយោជន៍ទល់នឹងបន្ទុក អ្នកអាចប្រើប្រាស់ការវិភាគសេណារីយ៉ូ ដើម្បីប្រៀបធៀបយុទ្ធសាស្ត្រអនុវត្តផ្សេងៗគ្នា។ | David Dow |
| 3 | តើចម្លើយចំពោះសំណួរនៅក្នុងវេទិកាសំណួរចម្លើយ ដែលមិនទាន់ទទួលបានក្នុងអំឡុងពេលនៃកិច្ចប្រជុំនេះ នឹងបញ្ជូនទៅដល់អ្នកចូលរួមនៅទីកន្លែងណា នៅពេលណា និងដោយរបៀបណា? | អនាមិក |
| 4 | ចំពោះអាទិភាពនានាដែលត្រូវបានលើកឡើងដោយ Jonathan នៅក្នុងបទបង្ហាញរបស់គាត់ តើមានចំនួនភាគរយណាមួយនៃមូលនិធិដែលអាចប្រើប្រាស់បានសម្រាប់តែអាទិភាពនានា ដូចជាការកាត់បន្ថយការបំពុលខ្យល់ ទល់នឹងចំនួនភាគរយនៃមូលនិធិដែលអាចប្រើប្រាស់បានសម្រាប់តែអាទិភាពទីពីរ ប្រជាជនយុត្តិធម៌បរិស្ថាន ដែរឬទេ? | David Queeley |

| | | |
|---|---|---|
| 5 | សូមអភ័យទោស សម្រាប់សំណួរយឺត និងសំណួរដែលមិនពាក់ព័ន្ធ។ យើងបានស្តាប់ឮនូវក្តីកង្វល់មួយចំនួនអំពីរបៀបដែលសាលក្រមរបស់តុលាការកំពូល ស្តីពីការបង្ការទប់ស្កាត់ការរើសអើងពូជសាសន៍ អាចប៉ះពាល់ចំពោះអំណាចរបស់រដ្ឋម៉ាសាឈូសិត ថាតើរដ្ឋនេះ អាចអនុវត្តគោលនយោបាយអាកាសធាតុ ពាក់ព័ន្ធនឹងយុត្តិធម៌បរិស្ថាន និងជាតិសាសន៍ដែរឬទេ។ តើក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន បានពិចារណាចំណុចនេះ ដូចដែលក្រុមប្រឹក្សានេះបានពិភាក្សាអំពីនិយមន័យ ដែលត្រូវបានធ្វើបច្ចុប្បន្នកម្មដែរឬទេ? នេះគឺជាអត្ថបទថ្មីមួយសម្រាប់ធ្វើជាឯកសារយោង។ សូមអរគុណចំពោះការបំពេញការងារនិងភាពជាអ្នកដឹកនាំ របស់អ្នក។ https://commonwealthmagazine.org/opinion/could-supreme-courts-admissions-decision-affect-mass-climate-law/ | Isabella Gambill |

## 11. ជំហានបន្ទាប់ និងការលើកវារកាល

- **María Belén** ស្នើសុំលើកវារកាល។ កិច្ចប្រជុំ ត្រូវបានលើកវារកាល នៅម៉ោង7:40 យប់។